ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១១)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia CARWRIGHT)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

លោក ធូ មណី

លោក យូរ ឧត្តរា (បម្រុង)

លោកស្រី ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ គុលវុឌ្ឍី

លោក លឹម ស៊ុយហុង

លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌ័រ បេ៊ត

*(Mr. Alexander BATES)*

លោក ពេជ្រ សម្បត្តិ

លោក ស្តាត ហ្វដ *(Mr.Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UŇAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

កញ្ញា ទី ស្រីណា

លោក យ៉ុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក ហ្វីលីប កាណុន

*(Mr. Philippe CANONNE)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច
សួរដោយ ចៅក្រម យ៉ា សុខន ចាប់ផ្តើមបន្ត.............................................................ទំព័រ ៧

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសាដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ប្រធានអង្គជំនុំ (ចៅក្រម និល ណុន) | ខ្មែរ |
| ចៅក្រម យ៉ា សុខន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកាន់បន្ទប់សវនាការ]*

[០៩:៣០:៤៧]

**ប្រធានអង្គជំនុំះ**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលតទៅទៀត ។

ហើយនៅព្រឹកនេះ មុននឹងចូលដល់កិច្ចដំណើរការនីតិវិធីសួរចម្លើយជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុនៃការបង្កើតមន្ទីរស-២១ និងគុកនៅតាខ្មៅនោះ អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចមួយស្តីពីពន្យារពេលកំណត់ក្នុងការសម្រេចលើការស្នើសុំឱ្យដោះលែងជនជាប់ចោទនៅក្រៅឃុំ ។

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើផ្ទាល់មាត់របស់សហមេធាវីការពារក្តីស្នើសុំឱ្យដោះលែងជនជាប់ចោទនៅក្រៅឃុំ ។ អនុលោមតាមវិធាន៨២.៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននិងនៅក្នុងគ្រប់ករណីទាំងអស់ត្រូវសម្រេចក្នុងរយៈពេលមិនឱ្យលើសពី៣០ថ្ងៃ ។ បន្ទាប់ពីទទួលបានពាក្យសុំដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ លើកលែងតែមានកាលៈទេសៈពិសេសដែលតម្រូវឱ្យមានរយៈពេលយូរជាងនេះ ។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សំណើសុំឱ្យដោះលែងបានធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ជាច្រើនដែលក្នុងចំណោមការចោទប្រកាន់ទាំងនោះ មានការចោទប្រកាន់ដែលថាការឃុំខ្លួនជនជាប់ចោទត្រូវបានពន្យារពេលដោយមិនត្រឹមត្រូវ និងការឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាការបន្តការឃុំខ្លួនរបស់តុលាការយោធា ។

ដើម្បីវាយតម្លៃលើការចោទប្រកាន់ទាំងនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះត្រូវពិនិត្យមើលសំណុំរឿងរបស់តុលាការយោធា ។

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៩ តាមរយៈការិយាល័យរដ្ឋបាល អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំតុលាការយោធាឱ្យផ្តល់សំណុំរឿងទាក់ទងនឹងការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធា ។ សូមកែតម្រូវវិញ នៅថ្ងៃទី០៦ ខែមេសា ។ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ តាមរយៈការិយាល័យរដ្ឋបាលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំតុលាការយោធាឱ្យផ្តល់សំណុំរឿងទាក់ទងនឹងការឃុំខ្លួនជន

ជាប់ចោទដោយតុលាការយោធា ។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងទទួលបានច្បាស់ចម្លងសំណុំរឿងរបស់តុលាការយោធាពីការិយាល័យរដ្ឋបាល ។ ឯកសារសំណុំរឿងទាំងអស់ត្រូវបានសរសេរជាភាសាខ្មែរ និងត្រូវបានស្នើសុំឲ្យមកប្រែភាសាអង់គ្លេសនិងភាសាបារាំង ។

[០៩:៣៤:២០]

ផ្នែកបកប្រែបានជម្រាបមកអង្គជំនុំជម្រះសាលាដំបូងថា ការបកប្រែឯកសារទាំងនេះជាភាសាអង់គ្លេសនិងភាសាបារាំង និងត្រូវបកប្រែរួចនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ ។ លើសពីនេះទៅទៀតអង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីបានដាក់ឯកសារជាលាយលក្ខណ៍អក្សរដែលគាំទ្រដល់ការស្នើសុំជាភាសាខ្មែរ និងភាសាបារាំងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ ពោល គឺ១០ថ្ងៃបន្ទាប់ពីការស្នើសុំលើកដំបូង ។

ជាចុងក្រោយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានការឈប់សម្រាកមួយសប្តាហ៍ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ និងការឈប់សម្រាកនាពេលខាងមុខ ជាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ ។ ក្រោយពីទទួលសំណៅបកប្រែសំណុំរឿងតុលាការយោធា ភាគីនានាមានរយៈពេល១០ថ្ងៃដើម្បីផ្តល់មតិយោបល់របស់ខ្លួន ។

ហេតុដូច្នេះ ដើម្បីផ្តល់ឲ្យភាគីនានាមានរយៈពេលគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងរយៈពេលគ្រប់គ្រាន់សម្រាប់ឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ និងមានមូលហេតុ។

អង្គជំនុំជម្រះសម្រេចថា កាលៈទេសៈមានអាទិភាព ដែលតម្រូវឲ្យមានការពន្យារពេលវេលាចេញសេចក្តីសម្រេចលើការស្នើសុំឲ្យដោះលែងជនជាប់ចោទនៅក្រៅឃុំបានចំនួន៤៥ថ្ងៃទៀត ។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើការស្នើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ។

ហើយជាកិច្ចបន្តយើងធ្វើសវនាការសួរចម្លើយជនជាប់ចោទ ពាក់ព័ន្ធទៅនឹងអង្គហេតុ ។ អ៊ីចឹងសូមបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងរង្វង់ក្រចកសេះ ។

ជាកិច្ចបន្តទៅនេះ សូមប្រគល់វេទិកាជូនទៅលោកចៅក្រម យ៉ា សុខន ដើម្បីបន្តសួរសំណួរដល់ជនជាប់ចោទ ។ សូមអញ្ជើញលោកចៅក្រម ។

**ចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

[០៩:៣៧:៣៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

បើអ៊ីចឹងខ្ញុំយល់ថាមានបញ្ហាបកប្រែទៀតហើយកាលិពីយប់មិញ បន្ទាប់ពីបានពិនិត្យមើលអ្វីៗផ្សេងៗជាមួយនឹងជនជាប់ចោទ ។ ខ្ញុំចង់ឲ្យគាត់នឹងជាជនជាប់ចោទនឹង ត្រូវធ្វើការបញ្ជាក់ឡើងវិញអំពីខ្សែរយៈបណ្ដោយ និងខ្សែរយៈទទឹង អ្វីដែលនិយាយជាភាសាខ្មែរ និងអ្វីដែលបានធ្វើការបកប្រែជាភាសាទាក់ទនទៅនឹងចំណុចទាំងពីរនេះ ។

បើអ៊ីចឹងខ្ញុំចង់ឲ្យសាលសវនាការនឹងបកត្រឡប់ទៅចំណុចនេះវិញ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយច៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកហ្វ្រង់ស្វ័រ រូ ។ ខ្ញុំចង់បញ្ចេញមតិបន្តិចប្រាប់ដល់ជនជាប់ចោទ ខ្ញុំយល់ថានឹងមានអត្ថប្រយោជន៍ណាស់សម្រាប់អ្នកបកប្រែ ប្រសិនបើគាត់អាចនិយាយឲ្យបានយឺតបំផុត ហើយនិងឲ្យចម្លើយរបស់គាត់នឹងខ្លីៗ ហើយសូមកុំឲ្យគាត់ផ្ដល់ឧទាហរណ៍ច្រើន ។ តើលោកអាចធ្វើអ៊ីចឹងបានទេបាទ? បើបានសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកហ្វ្រង់ស្វ័រ រូ នៅតែមានតែការបំណងចង់ឲ្យគាត់ឆ្លើយបញ្ជាក់ឡើងវិញអំពីប្រព័ន្ធនៃការគ្រប់គ្រងតាមខ្សែបណ្ដោយនិងខ្សែទទឹងទៀតទេ? ដោយការដែលគាត់លើកឡើងពីម្សិលមិញ គាត់បានលើកឡើងយ៉ាងច្បាស់លាស់ជាភាសាខ្មែរ អំពីយន្តការនៃចំណាត់ការតាមប្រព័ន្ធគ្រប់គ្រងតាមរយៈខ្សែបណ្ដោយនិងខ្សែទទឹងនៃកិច្ចការជំនាញនិងកិច្ចការគ្រប់គ្រងរដ្ឋ ។ ប៉ុន្តែ ដោយសារភាពច្បាស់លាស់នៅក្នុងការឆ្លើយ គាត់បានលើកនូវឧទាហរណ៍ ដែលយកឯកសារពីសំណុំរឿងលេខ០០២ មកឧទាហរណ៍រហូតដល់ខាងតំណាងខាងសហព្រះរាជអាជ្ញាគាត់បានលើកឡើងពីបញ្ហានេះ ដោយហេតុផលនៃឧទាហរណ៍ទេពុំមែនជាឯកសារភស្តុតាងសម្រាប់យកមកដេញដោលនៅក្នុងអង្គហេតុក្នុងរឿងនេះទេ ។ ដោយសារមូលហេតុ នៃការបកប្រែខ្ញុំមិនច្បាស់ទេ ប៉ុន្តែ ជាភាសាខ្មែរគឺមានន័យច្បាស់លាស់នៅក្នុងការ

បញ្ជាក់នូវអ្វីដែលជាការបង្ហាញ ហើយមានឧទាហរណ៍ជាការបញ្ជាក់ដើម្បីឲ្យការបង្ហាញនេះគឺច្បាស់លាស់ប៉ុណ្ណោះទេ ។ ប៉ុន្តែ គឺមានការភ័ន្តច្រឡំថា យកបញ្ហារឿងករណីទីពីរមកផ្ទុះបញ្ចាំងនៅ មកឆ្លើយបញ្ជាក់នៅក្នុងរឿងទីមួយទៅវិញ ។ អានេះជាបញ្ហាដែលនាំឲ្យមានការភ័ន្តច្រឡំ អ៊ីចឹងហើយបានជាលោកស្រី ស៊ីលយ៉ា ខាតវ៉ាយថ៍ លោកបានលើកឡើងអម្បាញ់មិញថា គួរតែត្រូវបានឲ្យខ្លីឲ្យច្បាស់ ហើយកុំឲ្យការឧទាហរណ៍វែងឆ្ងាយ ។ អានឹងវាជារឿងមួយដែលនាំវា វា១កាន់តែពន្លាតនូវបញ្ហាស្មុគស្មាញកាន់តែស្មុគស្មាញឡើង ។ ហើយការដែលយើងនិយាយកាន់តែច្រើនកាន់តែវែងទៅ វាពេលវេលាក៏ច្រើន ហើយសំខាន់អ្នកបកប្រែភាសាឯណោះ ដែលវាជាការងារលំបាកនៅក្នុងការបកប្រែភាសា ។ ហើយភាសាបកប្រែពីខ្មែរទៅអង់គ្លេស ហើយបកប្រែពីអង់គ្លេសទៅបារាំងទៀត វាដូចជាម្សិលមិញដែលភាគីទាំងអស់បានលើកឡើងពីចំណាប់អារម្មណ៍នូវការបាត់ បាត់នូវខ្លឹមសារ វាហាសិបភាគរយ ឬក៏អាន័យខ្លះវារហូតដល់ទៅអាចលើសពីហាសិបភាគរយទៅទៀត ។ អ៊ីចឹង វានាំឲ្យកិច្ចប្រតិបត្តិការ នៃដំណើរការរកយុត្តិធម៌របស់យើងនឹងគឺមានបញ្ហា ។

ហើយបញ្ហានេះគឺអង្គជំនុំជម្រះសាលាដំបូងបានជម្រាបពីម្សិលមិញហើយថា បានយកអាបញ្ហានេះដើម្បីទៅប្រជុំពិភាក្សានៅល្ងាចនេះ ហើយនិងនៅស្អែកនិងជាបន្តបន្ទាប់១ ដើម្បីចេញសេចក្តីសម្រេចហ្នឹង ឲ្យបានច្បាស់លាស់មុនពេលផ្តើមនូវអង្គហេតុបន្តបន្ទាប់ទៀត ដើម្បីឲ្យវាកិច្ចការប្រព្រឹត្តទៅនឹងគឺបានត្រឹមត្រូវ ។ ឥឡូវនេះចង់ឲ្យគាត់បញ្ជាក់ឡើងវិញទេបញ្ហានេះ?

[០៩:៤២:៤០]

**លោក ហ្រង់ស្វ័រ រូ៖**

បាទ, លោកប្រធាន ។ ខ្ញុំសូមឲ្យជនជាប់ចោទបញ្ជាក់ពីការថ្លែងរបស់គាត់ឡើងវិញ ទាក់ទងទៅនឹងទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រព័ន្ធរចនាសម្ព័ន្ធសន្តិសុខរបស់គេនោះ ។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្កេកអ៊ាវ លោកយល់នូវបំណងនៃការស្នើសុំរបស់លោកមេធាវីរបស់លោកហើយអ៊ីចឹងលោកសូមនិយាយអំពីបញ្ហានេះម្តងទៀត ។

**ជនជាប់ចោទ៖**

សូមអរគុណលោកប្រធាន និងសូមជម្រាបប្រសាសន៍លោកប្រធានថា សេចក្តីពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីការងារអ្វីក៏ដោយ និយាយឲ្យចំហើយជាពិសេសនៅពេលនេះគឺការងារ

សន្តិសុខ ។ ការងារសន្តិសុខនេះមិនដែលបានធ្វើតាមខ្សែទទឹងទេ មិនដែលទាល់តែសោះ ។ ម្សិលមិញខ្ញុំជឿថាខ្ញុំមិនច្រឡំមាត់ទេ ក៏ប៉ុន្តែព្រឹកមិញនេះមេធាវីការពារថាសេចក្តីបកប្រែជាភាសាបារាំងថាមានការទាក់ទងខ្សែទទឹង ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់នៅពេលនេះថា គ្មានការទាក់ទងតាមខ្សែទទឹងទេ ។ ហើយឧទាហរណ៍ដែលខ្ញុំខំលើកទាំងប៉ុន្មាននេះ គឺដើម្បីបញ្ជាក់ថាមានតែខ្សែបណ្តោយ គឺពីស-២១ទៅលើ ហើយពីលើទៅភូមិភាគ ឬក៏ពីលើនោះទៅមន្ទីរផ្សេងៗទៀត និងកងពលផ្សេងៗទៀតនៅភ្នំពេញ ។ នេះខ្ញុំសុំលើកឧទាហរណ៍ខ្លី ។

សរុបមកវិញ គឺខ្ញុំចង់បញ្ជាក់ថាការងារសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ គ្មានការទាក់ទងតាមខ្សែទទឹងរវាងមន្ទីរសន្តិសុខនិងមន្ទីរសន្តិសុខទេ ។ សូមលោកប្រធានជ្រាប ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម យ៉ា សុខន បន្ត ។ លោក ហ្សង់ម៉ាក មានបញ្ហា! សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តាមពិតខ្ញុំចង់ដឹងឲ្យច្បាស់ពីបញ្ហានេះ ពីព្រោះខ្ញុំ ខ្ញុំមិនយល់ផ្ទុយពីហ្នឹងពីអ្វីដែលខ្ញុំឮពីម្សិលមិញនោះ គឺវាផ្ទុយស្រឡះ ។

ខ្ញុំចង់ដឹងថែមទៀត ថាតើលោកនិយាយជាកំហុសបកប្រែ ឬក៏យើងប្រឈមមុខទៅនឹងបញ្ហានៃការយល់ដឹងពីបញ្ហាហ្នឹង? ឬក៏ជាបញ្ហាគឺភាពស្របគ្នា ដែលអ្វីដែលជនជាប់ចោទបាននិយាយ ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតដើម្បីបញ្ជាក់ឡើងវិញអំពីខ្លឹមសារនៃប្រតិចារឹកជាភាសាខ្មែរ ។

ម្សិលមិញខ្ញុំបានឮថា គឺវាមានទំនាក់ទំនងខ្សែទទឹងរវាងមន្ទីរសន្តិសុខទៅមន្ទីរសន្តិសុខ ប៉ុន្តែថ្ងៃនេះខ្ញុំយល់ថា ប្រហែលតាមពិតគឺវាពិបាកនឹងយល់ ថាតើមានទំនាក់ទំនងតែខ្សែទទឹង-- មានតែខ្សែបណ្តោយ-- អ្នកបកប្រែសូមកែ គឺវាមានតែទំនាក់ទំនងតែខ្សែបណ្តោយ មិនមានទំនាក់ទំនងខ្សែទទឹងទេ ។ អ៊ីចឹង គឺថា--

**លោក ហ្សង់ស្វ័រ រូ៖**

គឺថាបានពិភាក្សាលម្អិតពីជាមួយសហចៅក្រមស៊ើបអង្កេត ហើយលោកចៅក្រមអាចនឹងឃើញនៅក្នុងកំណត់កត់ត្រាលាយលក្ខណ៍អក្សរជនជាប់ចោទនិយាយច្បាស់ថា មិនមានទំនាក់ទំនងរវាងមន្ទីរ

សន្តិសុខនិងសន្តិសុខ គឺថាវាមានតែទំនាក់ទំនងខ្សែបណ្ដោយពីកំពូលទៅថ្នាក់ក្រោម ឬក៏ពីថ្នាក់ក្រោមទៅថ្នាក់កំពូល ។ អ៊ីចឹង ជាសេចក្ដីលម្អិតនោះគឺយើងបានបញ្ជាក់ទៅដល់សហចៅក្រមស៊ើបអង្កេត ហើយខ្ញុំមានការភ្ញាក់ផ្អើលដែលថា លោកចៅក្រមម្សិលមិញបានឮផ្ទុយពីហ្នឹងទៅវិញ ។ អ៊ីចឹង ហើយខ្ញុំក៏មានការរំភើបតក់ស្លុតដែរ ដែលថាបានឮលោកចៅក្រមយល់ដូច្នេះនោះ ។ អ៊ីចឹងហើយ តើប្រតិចារឹកនុំង កត់ត្រាបានដូចម្ដេចពីម្សិលមិញនោះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នេះហើយមិននិយាយនៅក្នុងដំណាក់កាលស៊ើបអង្កេតទេ គឺយើងនិយាយពីអ្វីដែលជនជាប់ចោទនិយាយនៅក្នុងសវនាការម្សិលមិញ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកចៅក្រម យ៉ា សុខន បន្តការងាររបស់លោកតទៅទៀត ។

[០៩:៤៨:២០]

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ជនជាប់ចោទ កាលពីម្សិលមិញ លោកបានបញ្ជាក់ថា លិខិតចុះថ្ងៃទី៣០ ខែ៦ ឆ្នាំ១៩៧៦ និងលិខិតចុះថ្ងៃទី៩ ខែ១០ ឆ្នាំ១៩៧៥ ជាលិខិតដែលពុំមានចុះត្រាឬក៏ហត្ថលេខាទេ ។ តើលិខិតនោះជាលិខិតអ្វី? ហើយលិខិតនោះមាននៅក្នុងសំណុំរឿងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម លិខិតនេះជាសេចក្ដីសម្រេចចិត្តរបស់អចិន្ត្រៃយ៍មជ្ឈិមបក្ស ។ លិខិតទាំងពីរនេះ សហព្រះរាជអាជ្ញាក៏ប្រើនៅក្នុងដីកាសន្និដ្ឋានស្ថាពរ ។ សហចៅក្រមស៊ើបអង្កេតក៏ប្រើនៅក្នុងសេចក្ដីបញ្ជូនសំណុំរឿងមកជំនុំជម្រះ ។

វាមើល-- ខ្ញុំសុំអនុញ្ញាតពេលវេលាមើលសំណុំរឿងនេះ ជាលេខ *អ៊ីអ័រអិន* (ERN) ជូនលោកចៅក្រម ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

លោកចៅក្រម ខ្ញុំសុំជួយផ្ដល់ ERN លេខERN នៅក្នុងភាសាទាំងបី បើសិនជា-- គឺជាផ្នែកនៃសំណុំរឿងមែន ត្រូវបានដាក់ជូននៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយនៅក្នុងដីកាដំណោះស្រាយផងដែរ ហើយនៅក្នុងឧបសម្ព័ន្ធ *ស៊ី* (គ) គឺថា២៦.៣ នៅក្នុងភាសាខ្មែរ ERN នុំង គឺ 0003136 រហូតទៅដល់ 3142 នៅអង់គ្លេស 00182809 ទៅដល់ 844 នៅក្នុងបារាំង គឺ 00446737 ។

ខ្ញុំអាចនឹងជូនជាចំណងជើងជាភាសាអង់គ្លេស ដែលហៅថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិម" ទាក់ទងទៅនឹងបញ្ហាមួយចំនួន ចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ ហើយទាក់ទងនឹងឯកសារដែលលោកចៅក្រមឲ្យពេលខ្ញុំមួយមីនុត ខ្ញុំអាចនឹងពិនិត្យមើលបន្ថែមបញ្ជាក់ទៀត ។

**លោក ហ្សង់ស្វ័រ រូ៖**

ប្រហែលជាទាក់ទងទៅនឹងឯកសារ ចុះខែតុលា នោះ គឺថា 30-- 00019108 រហូតទៅដល់ 00019126 ដែលលោកសហព្រះរាជអាជ្ញា លោកអាចពិនិត្យមើលឯកសារដែលមានលេខនោះ ។ ហើយនៅក្នុងអត្ថបទបកប្រែជាអង់គ្លេស គឺជាសេចក្តីព្រាងបកប្រែ បកប្រែព្រាងទេ ។

ដូច្នេះ នៅក្នុងភាសាអង់គ្លេស ERNលេខ00183393 រហូតទៅដល់ 00183408 ប៉ុន្តែអ្វីដែលនៅក្នុងសេចក្តីព្រាងនោះផងដែរ ខ្ញុំមិនមានអត្ថបទជាភាសាបារាំងទេ ។ លេខERN ហ្នឹងគឺ 00292868 - 00292886 នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងឯកសារ ១៣.២ ។

[០៩:៥៦:៥៤]

**ស្នងការរង ចៅក្រម យ៉ា សុខន៖**

**ស៖** តើលោកអាចបញ្ជាក់បានទេថា មន្ទីរសន្តិសុខនៅក្នុងរបបកម្ពុជាធិបតេយ្យមានប៉ុន្មានប្រភេទ? ហើយមន្ទីរស-២១ នេះ ចាត់ក្នុងប្រភេទណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ។ នៅពេលដែលខ្ញុំចូលមកដល់ អ.វ.ត.ក នេះ មន្ទីរសន្តិ-សុខផ្សេងទៀត ក្រៅពី ស-២១ ខ្ញុំស្គាល់តែមន្ទីរសុខកំពង់ធំមួយប៉ុណ្ណោះ ដែលប្អូនថ្លៃខ្ញុំវាកាន់កាប់ក្រោមការគ្រប់គ្រងរបស់ភូមិភាគកណ្តាល ។ ខ្ញុំស្គាល់នេះច្បាស់ពីព្រោះ នៅថ្ងៃ០១ ខែមករា ១៩៧៦ ខ្ញុំជូនម្តាយខ្ញុំទៅត្រឡប់ទៅផ្ទះវិញ ខ្ញុំចូលអាមន្ទីរសន្តិសុខនេះ ពីព្រោះក្នុងឋានៈជាបងថ្លៃ វាចូលទៅសួរប្អូនថ្លៃ ។ ទីពីរ មន្ទីរដែលខ្ញុំស្គាល់គឺមានតែមន្ទីរសុខ តំបន់៣២ របស់ភូមិភាគនិរតីចាស់ដែលហៅថា "បស្ទិមថ្មី" ដែលក្រោយមកហៅថា "បស្ទិម" ។ ដល់ក្រោយមកៗ បានខ្ញុំដឹងថាអាមន្ទីរសន្តិសុខនេះឈ្មោះ មន្ទីរ៨៩, ម-៨៩ ។ បានជាខ្ញុំស្គាល់ពីព្រោះមេឲ្យបញ្ជូនឈ្មោះ ហាម អ៊ុន-- ឲ្យបញ្ជូនឈ្មោះ ហាម អ៊ីុន ទៅនៅហ្នឹងមន្ទីរនោះ ទទួលទោសបន្តទៀត ជាអ្នកពាក់កណ្តាលអ្នកមានទោស ។

សរុបមក មុននឹងចូលមក អ.វ.ត.ក នេះ ខ្ញុំស្គាល់មន្ទីរសន្តិសុខផ្សេងទៀតក្រៅពី ស-២១ មានតែពីរហ្នឹងឯង ។ ដល់ក្រោយមកបានខ្ញុំដឹងថា មានមន្ទីរសន្តិសុខស្ទើរតែគ្រប់ភូមិភាគ មិន--(សូមទោស) ដល់ក្រោយមកបានខ្ញុំដឹងថាមានមន្ទីរសន្តិសុខផ្សេងៗទៀតជាច្រើន ។

[១០:០១:០៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក មានបញ្ហាអី?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា កុំឲ្យថានេះជា-- មានបញ្ហា ពីព្រោះខ្ញុំបានឮពីរដង ជនជាប់ចោទបាននិយាយថា គាត់បានដឹងមន្ទីរសន្តិសុខតែពីរ មុននឹងគាត់មកដល់ អ.វ.ត.ក នេះ តើនេះជាព័ត៌មានត្រឹមត្រូវទេ? តើនេះគឺជាអ្វីដែលលោកនិយាយឬ? មានន័យថា លោកបានដឹងទីតាំងមន្ទីរសន្តិសុខតែពីរផ្សេងទៀតទេ មុនពេលដែលលោកមកដល់ អ.វ.ត.ក នេះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម និយាយថាមុនមកដល់ *សេអឺតេសេ* (CETC) ក៏បាន និយាយថាមុនមកដល់តុលាការ *មីលីទែរ* (Militaire) ក៏បានដែរ ។ សូមបញ្ជាក់បន្ថែមថា១ ខ្ញុំស្គាល់អាមន្ទីរនគរបាលតំបន់-- (សូមទោស) មន្ទីរនគរបាលតំបន់កំពង់ធំ មកពីប្អូនថ្លៃខ្ញុំវាកាន់កាប់នៅនុំង ។ ដូច្នេះខ្ញុំមក ខ្ញុំចូលទៅសួរទុក្ខប្អូនថ្លៃក្នុងឋានៈជាឯកជន ក្រៅផ្លូវការ ។

ទីពីរ មន្ទីរម-៩៩ ជាបញ្ជារបស់លោកគ្រូ សុន សេន មេខ្ញុំ ឲ្យបញ្ជូនអ្នកដែលរងគ្រោះនៅមន្ទីរ១៣ នេះទៅនៅក្នុងមន្ទីរម-៩៩ នេះជាបញ្ជារបស់មេដែលខ្ញុំធ្វើតាម ។ សូមបញ្ជាក់ថា ម-១៣ វានៅតែជាអង្គភាពរបស់មន្ទីរភូមិភាគពិសេស ហើយមកចប់ត្រឹមថ្ងៃ៣០ មីនា (សូមទោស) ៣០ មេសា ១៩៧៥ ដែលខ្ញុំបញ្ជូនអ្នកទោសប៉ុន្មាននាក់ពីរ-បីនាក់ហ្នឹងទៅទីនុំងតាមបញ្ជា ។ ឯចំណែក មន្ទីរម-៩៩ គេមានតាំងពីដើមមកហើយគេដំណើរការរហូតមកតមកទៀត ។ វាជាកម្មសិទ្ធិរបស់ភូមិភាគបស្ចិម ដូច្នេះដាច់ដោយឡែកពីគ្នា គ្មានខ្សែទាក់ទងទទឹងទេ ។

[១០:០៥:២២]

**ចៅក្រម យ៉ា សុខន៖**

**ស៖** លោកមិនទាន់បានបញ្ជាក់ថា មន្ទីរស-២១ នេះ ចំណាត់ថ្នាក់ក្នុងប្រភេទណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រមមន្ទីរស-២១ វាជាមន្ទីរដែលនៅក្រោមការគ្រប់គ្រងរបស់លោកគ្រូ សុន សេន ឯកសារថ្ងៃ៩ តុលា ជាភស្តុតាងស្រាប់ ។ នៅខាងចុងទំព័រក្រោមគេបំផុតលេខ៦ សរសេរថា នៅចុងគេបំផុតនៃទំព័រទីមួយ ត្រង់លេខប្រាំមួយសរសេរថា "សមមិត្ត ខៀវ ទទួលសេនា-

ធិការនិងសន្តិសុខ" ។ ត្រង់ "ខ" ទី៦-- លេខ៦-- ត្រង់លេខ៦ សរសេរថា "សមមិត្ត ខៀវ ទទួលខាងសេនាធិការនិងខាងសន្តិសុខ" សូមបញ្ជាក់ជូនលោកចៅក្រមថា សមមិត្ត ខៀវ គឺលោកគ្រូ សុន សេន មេខ្ញុំ ។

ហើយសូមបញ្ជាក់បន្តទៅទៀតថា ឯកសារទាំងអស់នៅស-២១ សុទ្ធតែជាសេចក្តីដែលខ្ញុំសរសេរជូនទៅមេខ្ញុំ គឺលោកគ្រូ សុន សេន ។ ហើយបន្ទាប់មកទៀត ជូនទៅពូ នួន ជា ពីព្រោះគាត់មកបន្តវេនពីលោកគ្រូ សុន សេន ។ បន្តពីលោកគ្រូ សុន សេន នៅពេលដែលលោកគ្រូ សុន សេន អញ្ជើញទៅសមរភូមិមុខ ។ សូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** អ៊ីចឹងគឺបានយោងទៅលើឯកសារមួយ តើយើងអាចមានលេខឯកសារហ្នឹងបានទេ? ដូចដែលខ្ញុំបាននិយាយពីមុនអ៊ីចឹង នៅពេលដែលបានដកស្រង់ពីឯកសារណាមួយហ្នឹង គឺថាយើងត្រូវតែមានលេខយោងពិតប្រាកដអំពីឯកសារនោះ ។

[១០:០៩:៤៩]

**ឆ៖** ខ្ញុំជឿថា។លោកចៅក្រមតម្រូវឲ្យខ្ញុំយោងទៅឯកសារជាក់ស្តែងដែលចេញពីមន្ទីរស-២១។

**ស៖** បើសិនជាខ្ញុំ-- លើកលែងតែខ្ញុំច្រឡំ ប៉ុន្តែលោកបាននិយាយអំពីឯកសារជាក់លាក់មួយនៅក្នុងចម្លើយរបស់លោក ។ តើលោកអាចប្រាប់លេខយោងលេខ, លេខ ERN របស់ឯកសារនុ៎ងបានទេ?

**ឆ៖** អរគុណដែលលោចៅក្រមទាមទារឲ្យខ្ញុំបញ្ជាក់ ។ ខ្ញុំសូមបញ្ជាក់ថា ឯកសារថ្ងៃ៩ ខែតុលា ឆ្នាំ១៩៧៥ មានលេខ ERN00019108 រហូតដល់ 00019126 ។ ចំណែក ខ្លឹមសារដែលខ្ញុំបាទ យោងអម្បាញ់មិញគឺនៅ ERN00019108 ។ ឯខ្លឹមសារដែលយើងខ្ញុំនិយាយយោងអម្បាញ់មិញថា លោកគ្រូ សុន សេន ជាមេខ្ញុំស្ថិតនៅទំព័រ000190108 គឺទំព័រខាងដើមដែលយើងហៅថាទំព័រទី១ ។ សូមបញ្ចប់។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំចង់បញ្ជាក់ថែមថា ទំព័រត្រឹមត្រូវលើភាសាអង់គ្លេសនោះ គឺមានលេខ00183393 ។ ហើយឯកសារហ្នឹង គឺនៅក្នុងកថាខណ្ឌ-- អត្ថបទហ្នឹង គឺនៅក្នុងកថាខណ្ឌទី៦ ។ សម្រាប់ភាសាបារាំងវិញ គឺ

មានលេខ00292868 ។ អ៊ីចឹងគឺដូចគ្នាដែរ គឺនៅក្នុងកថាខណ្ឌទី៦-- ហើយជាភាសាបារាំងនេះ គឺជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ៧៥ ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** សូមលោកបញ្ជាក់មកមើល៎! តើការបង្កើតមន្ទីរស-២១ នេះ មានភារកិច្ចធ្វើអ្វី?

**ឆ៖** លោកចៅក្រមជាទីគោរព ខ្ញុំសូមជម្រាប់ប្រសាសន៍ថា គ្រប់មន្ទីរសន្តិសុខទាំងអស់ៗរួមទាំងមន្ទីរស-២១ផង មានភារកិច្ចទទួលឃុំឃាំងធ្វើទារុណកម្មសួរចម្លើយ ហើយចុងបញ្ចប់កម្ទេចគឺយក ទៅសម្លាប់ ។

**ស៖** សូមក្រឡាបញ្ជីឲ្យបង្ហាញឯកសារលេខ00153467 នៅលើអេក្រង់កុំព្យូទ័រ ។ នេះគឺជាប្លង់ទីតាំងមន្ទីរស-២១ លោកបានបញ្ជាក់ពីម្សិលមិញ ទីតាំងដំបូងនៃមន្ទីរស-២១ នៅចំណុចអា “A”ៗ ។ នៅពេលនោះ លោកក៏បានបញ្ជាក់បន្ថែមថានៅពេលមានទីតាំងលើចំណុច “A” នេះ ប្រធាននៃមន្ទីរស-២១ កាលណោះ គឺលោក ណាត ពេលនោះលោកជាអនុប្រធាន ។ ហើយលោកបានបន្តបន្ថែមទៀតថាទីតាំងនេះបានដូរទៅគុកធំ ប៉េហ្ស៊ី (PJ) ហើយត្រឡប់មកទីតាំងចាស់វិញ តើមូលហេតុអ្វីបានជាមានការផ្លាស់ប្តូរទីតាំងក្នុងរយៈពេលដ៏ខ្លីជាច្រើនដងយ៉ាងដូច្នេះ?

[១០:១៧:៥៩]

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម នៅពេលនោះ ណាត គាត់ជាប្រធាន ការផ្លាស់ប្តូរនេះយើងខ្ញុំអត់បានពិគ្រោះគ្នាទេ ។ ពេលនេះ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំរាយការណ៍ជូនក្នុងឋានៈជាការវិភាគនិងសន្និដ្ឋាន ។

កាលដែលយកមនុស្សមកសួរចម្លើយនៅត្រង់ចំណុច “A” គឺចន្លោះផ្លូវលេខ៣៦០ និងផ្លូវលេខ១៦៣ នេះ វាជាផ្ទះល្វែង-- វាជាផ្ទះរបស់មនុស្ស របស់មហាជន ។ ដូច្នេះ ពិបាកក្នុងការគ្រប់គ្រងអ្នកទោសពេលសួរ ។ យ៉ាងនេះហើយបានៗជា ណាត គាត់ផ្លាស់ទៅឯខាង ប៉េហ្ស៊ី ។ នេះជារឿងដែលខ្ញុំសន្និដ្ឋានដោយសុទ្ធសាធ ។ ចំណែកផ្លាស់ពីប៉េហ្ស៊ីមកកន្លែងដើមវិញមក កន្លែងនេះវិញ មកកន្លែង “A” នេះវិញដោយសារមេដេញ ។ នៅទីនោះចំហ ភ្ញៀវចិនឃើញ ។ នេះខ្ញុំសូមជម្រាបបញ្ជាក់បានត្រឹមតែប៉ុណ្ណោះឯង (សូមទោស) ។

**ស៖** លោកក៏បានបញ្ជាក់កាលពីម្សិលមិញ ពីបញ្ហារចនាសម្ព័ន្ធក្នុងការរៀបចំ ស-២១ កាលណាត ធ្វើជាប្រធាន ។ តើលោកអាចបញ្ជាប់ឲ្យបានច្បាស់ជាងនេះតទៅទៀតបានទេ តើនៅក្នុងពេល

ដែល ណាត ធ្វើជាប្រធាននៅមន្ទីរស-២១ ដូចដែលបានលោករៀបរាប់ខាងលើអម្បាញ់មិញនេះ តើមានអង្គការលេខជាក់លាក់ក្នុងការរៀបចំដឹកនាំមន្ទីរនេះឲ្យបានទេៗ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម សម័យដែល ណាត ធ្វើជាប្រធាន ខ្ញុំអត់មានគិតគូរទាមទារសុំធ្វើអង្គលេខទេ ។ ហើយសមាសភាគកម្លាំងដែលនៅទីនោះ ក៏ខ្ញុំមិនទាមទារចង់ដឹងដែរ ព្រោះរឿងគេជាអ្នកគ្រប់គ្រង ខ្ញុំមិនលូកដៃទេការងារហ្នឹង ខ្ញុំអត់សួរចង់ធ្វើផង ទុកឲ្យគេធ្វើចុះ ។ ខ្ញុំដឹងតែការងារអី ដែលគេឲ្យខ្ញុំធ្វើ ខ្ញុំធ្វើ ។

ដូច្នេះសរុបមកវិញ ខ្ញុំអាចគ្រាន់តែសង្ខេបបានថា ការងារប្រចាំថ្ងៃគ្រប់យ៉ាងស្ថិតនៅលើមិត្តហ៊ឈ្មោះដើម ឃឹម វ៉ាក ដែលជាបុគ្គលទីបីនៃ ស-២១ ពេលកកើតដំបូង គ្រប់យ៉ាងគ្នារត់សព្វមុខ ។ នេះខ្ញុំសូមបញ្ជាក់ជូនបានត្រឹមប៉ុណ្ណេះ ។ សូមអស់ ។

[១០:២២:៥០]

**ស៖** ពីម្សិលមិញ គឺលោកបានបញ្ជាក់ដែលថាបុគ្គលិកដែលយកមកធ្វើការនៅមន្ទីរ ស-២១ នេះយកពីកងពលលេខ៧០៣ ម-១៣ និងក្រុមសម្ងាត់ ។ តើនៅពេលដែលលោកយកបុគ្គលិកពីមន្ទីរម-១៣ មកយកតែអ្នកជំនាញខាងសួរចម្លើយ ឬយកទាំងអ្នកការពារមកជាមួយ យកមកការពារ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ពួកយុទ្ធជនកម្មាភិបាលដែលមកពីម-១៣ គឺបញ្ចូលភាគច្រើនលើសលប់ទៅខាងសួរចម្លើយ (សូមទោស) សូមនិយាយម្តងទៀតខាងបកប្រែ ។ ពួកកម្មាភិបាលយុទ្ធជនដែលខ្ញុំយកមកពីម-១៣ បញ្ចូលទៅខាងក្រុមសួរចម្លើយស្ទើរតែគ្រប់គ្នា ។ ក្រៅពីនោះ មានពីរ-បីនាក់ជានីរសាររបស់ខ្ញុំផ្ទាល់ ។ ក្រៅពីនោះ មានពីរនាក់ៗ ខ្ញុំចាត់តាំងជានីរសាររបស់ខ្ញុំ ។ នេះសូមជម្រាបលោកចៅក្រមអំពីសមាសភាពមកពីម-១៣ ។

**ស៖** តើលោកនៅចាំទេថា អ្នកសួរចម្លើយដែលយកមកពីម-១៣ មានឈ្មោះអ្វីខ្លះទៅ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម អ្នកដែលខ្ញុំយកមកពីម-១៣ ហើយឲ្យនៅខាងសួរចម្លើយមានដូចតទៅ៖

ទី១) គឺបង ម៉ម ណៃ ហៅ ចាន់ៗ ដែលម្សិលមិញ ខ្ញុំបាទបានរៀបរាប់ច្បាស់លាស់អស់ហើយ គឺដល់ក្រោយមកខ្ញុំបានប្រើបុគ្គលរូបនេះៗជាអ្នកសួរចម្លើយឈ្លើយសឹកយួន និងប្រើជាជំនួយការរបស់ខ្ញុំ ។ បុគ្គលទី២ គឺ មិត្តប៉ុន ។ បុគ្គលនេះខ្ញុំបាទប្រើឲ្យសួរអ្នកទោសដែលសំខាន់ៗចាប់តាំងពីដើមរហូតដល់ចុងបញ្ចប់ បានន័យថារហូតដល់ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។ មិត្តផ្សេងទៀតមាន ពួកអ្នកដែលមក

ពីខាងភូមិថ្នគប់ ភូមិទំនាប និងភូមិត្រពាំងគ្រោប គឺទំនាប គឺអ្នកដែលមកពីភូមិថ្នគប់ មកពីភូមិទំនាបៗ ហើយនិងត្រពាំងគ្រោប ។ ភូមិត្រពាំងគ្រោបមានដូចតទៅ៖ ទីមួយឈ្មោះ មិត្តអុន នាមត្រកូលប្រហែលជាឈ្មោះ គីម ហើយទីពីរគឺ មិត្តណាន, ប្រាក់ ណាន នេះនៅភូមទំនាប ហើយនិងភូមិត្រពាំងគ្រោប ។ ហើយក្រៅពីនោះ សុទ្ធតែពួកមកពីខាងភូមិព្រៃជ្រៅមាន សា ទិត, ទឹម អឿន, ឈិន-- ម៉ុក ឈិន, ហើយមានម្នាក់មកពីខាងភូមិស្នួលគឺ មិត្តមាស ប៉ុន្តែគ្នាស្លាប់បាត់ហើយ ។ ក្រៅពីនេះ ខ្ញុំអត់ចាំឈ្មោះទេ អាចនៅខ្វះម្នាក់ពីរទៀត ។

[១០:៣០:៣៥]

**ស៖** កម្លាំងដែលយកមកពីកងពល-៧០៣ ហើយនិងកម្លាំងក្រុងនោះមានបានដកហូតយកមកធ្វើជាអ្នកសួរចម្លើយទេនៅពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម កម្លាំងមកពីក្រុងបញ្ចូលទៅជាអ្នកសួរចម្លើយទាំងអស់។ ឯចំណែកកម្លាំងមកពី ៧០៣ មានយកមួយចំនួនមកជាអ្នកសួរចម្លើយដែរ ។ សូមបញ្ចប់ ។

**ស៖** លោកត្រូវបានតែងតាំងជាប្រធាន ស-២១ នៅពេលណា? ហើយនៅលើទីតាំងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ពេលប្រហែលជាពាក់កណ្ដាលខែមីនា ១៩៧៦ មេហៅខ្ញុំនិងណាត ទៅធ្វើការដូចធម្មតា ។ ពេលហ្នឹងគាត់ថា ស-២១ ប្រគល់ឲ្យមិត្តឌុច កាន់កាប់ទៅ ទោះបីការងារយឺតបន្តិចក៏យឺតចុះ ឲ្យមិត្តឌុច ធ្វើទៅ ព្រោះមិត្តណាត មានការទៅផ្សេងទៀត ។ គាត់និយាយតែប៉ុណ្ណឹងឯងទេ ។ ហើយដល់ក្រោយមកបានគាត់និយាយទៀតថាឲ្យមិត្តណាត បង្ហើយការងារចាស់របស់ខ្លួនឲ្យហើយទៅ ។ ដូច្នេះ អ្នកដែលបញ្ជាឲ្យផ្លាស់ប្ដូរនេះគឺមេខ្ញុំ លោកគ្រូ សុន សេន ។ កន្លែងដែលចាត់តាំងផ្លាស់ប្ដូរនេះគឺនៅកន្លែងធ្វើការធម្មតា ។ បើសិនជាយកផែនទីភ្នំពេញមកដាក់ដែលខ្ញុំរាយការណ៍ជូននោះ គឺនៅទុំងមិញអក្សរ “B” ។ សូមបញ្ចប់ចម្លើយនេះប៉ុណ្ណេះ ។

**ស៖** ទីតាំងដែលលោកដែលគេចាត់តាំងឲ្យលោកធ្វើជាប្រធានស-២១ តើវាស្ថិតនៅលើទីតាំងនៅកែងផ្លូវ១៦៣ និង ៣៦០ ?

**ឆ៖** បាទទាន! ខ្ញុំសូមបញ្ជាក់ថាទីតាំងដែលចាត់តាំងខ្ញុំឲ្យធ្វើប្រធាននេះ គឺកន្លែងដែលខ្ញុំទៅធ្វើការជាមួយនឹងមេ ។ នៅលើផែនទីដែលខ្ញុំរាយការណ៍ជូនចៅក្រមស៊ើបអង្កេតរួចហើយ ផែនទីភ្នំពេញខ្ញុំដាក់អក្សរ “B” គឺនៅខាងជើងបុរីកីឡា ។ ផែនទីនេះមាននៅក្នុង--

**ចៅក្រម យ៉ា សុខន៖**

សូមក្រឡាបញ្ចើបង្ហាញទីតាំងនេះ ។

**ឆ៖** នេះផ្លូវសហព័ន្ធរុស្ស៊ីនេះ “B” មិនមែនផ្លូវសហព័ន្ធរុស្ស៊ី ត្រង់ចន្លោះផ្លូវលេខ៣២០ និងផ្លូវ ១២២ និង១១៨ ហ្នឹង ។ នេះកន្លែងនេះ កន្លែងដែលខ្ញុំចុចពង់មួយនេះ កន្លែងដែលខ្ញុំទៅធ្វើការជាមួយមេ ហើយគាត់ចាត់តាំងឲ្យខ្ញុំធ្វើប្រធាននៅហ្នឹង នៅកន្លែងហ្នឹង ។ ផ្ទះដែលខ្ញុំធ្វើការ ខ្ញុំគូជា *វេចតង់* (ជាប្អូនជ្រុងទ្រវែង) នៅលើដងផ្លូវ១១៨ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអភ័យទោសលោកប្រធាន ។ សូមឲ្យក្រឡាបញ្ចើបញ្ចុះផែនទីមកក្រោមបន្តិចដើម្បីឲ្យឃើញផ្លូវលេខ១១៨ ។ សូមអរគុណ ។

**ចៅក្រម យ៉ា សុខន៖**

**ស៖** នៅពេលដែលលោកធ្វើជាប្រធាននិងទទួលការចាត់តាំងធ្វើជាប្រធានមន្ទីរស-២១ នៅពេលនោះ ភ្លាម តើលោករៀបចំអង្គការលេខតែម្តងឬ?

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធាន អង្គជំនុំជម្រះ (សុំកាត់បន្តិច) តំណាងសហព្រះរាជអាជ្ញាចង់សុំឲ្យជនជាប់ចោទហ្នឹង គឺសុំបញ្ជាក់ពីប្លុកនៅលើផែនទីហ្នឹងបន្តិចថា តើប្លុកនោះវាមានប្លុក អេ, ប៊ី, ស៊ី, ឌី “A, B, C, D” ហ្នឹង ថាតើប្លុកនីមួយៗ ដើម្បីឲ្យអង្គសវនាការហ្នឹងយល់ថានៅលើផែនទីហ្នឹង ដែលមានផ្លូវ ១១៨ហ្នឹង ថាតើប្លុកនីមួយៗហ្នឹងជាប្លុកអី? ត្រង់ណាប្លុកជារ៉ាវទេះភ្លើង ត្រង់ណាជាក្រសួងការពារជាតិ ត្រង់ណាជាប្លុករបស់បុរីកីឡា? សូមឲ្យគាត់បញ្ជាក់ឡើងវិញតែប៉ុណ្ណឹង ។ បាទៗ អរគុណ ។

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា ។ ខ្ញុំសូមបញ្ជាក់ថា “A” នេះ ជាកន្លែងដែលខ្ញុំទទួលការខទ្មេសនាមឲ្យកកើតមន្ទីរស-២១ គឺស្ថានីយ៍រថភ្លើងក្រុងភ្នំពេញ ។ ទីពីរ “B” ជាកន្លែងដែលខ្ញុំធ្វើការជាមួយមេខ្ញុំលោកគ្រូ សុន សេន ចាប់តាំងប្រហែលជាខែ១០ (ខ្ញុំសូមទោស) ១៩៧៥ រហូតមក រហូតមកដល់ថ្ងៃ១៥ សីហា ១៩៧៧ ។ ឯចំណែក “C” គឺជាបុរីកីឡា ។ បុរីកីឡានេះ វាមានអគារមួយធំនេះនៅខាងត្បូងនេះៗបែរមុខមករកផ្លូវលេខ១៨២ ។ កន្លែងនេះហើយដែលពូ នួន ហៅខ្ញុំទៅធ្វើការដំបូង ហើយនិងមួយលើកពីរទៀត ។ សូមបញ្ជាក់ថា ពូនួន នេះគឺ នួន ជា ។ នៅក្នុងផ្ទៃក្នុងបក្សកាលណោះគេហៅ បងនួន ។ ហើយសូមបន្តបន្តិចទៅទៀត (សូមទៅលើៗ អត់ទេ ទាញទៅលើមកឲ្យឃើញផ្លូវ

សុធារស ទាញទៅលិចៗ ទាញៗអានេះទៅណោះទៀតបាន ។ នេះ “G” នេះ ដែលខ្ញុំសរសេរនេះ ចុះក្រោមៗបាន “G” ដែលខ្ញុំសរសេរនេះ គឺជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដែល ពួនួន ហៅខ្ញុំទៅធ្វើការញ៉ែកញាប់កន្លែងនេះជាងគេនេះ ។ សូមបញ្ចប់ការរាយការណ៍ជូនពីបញ្ហា នេះប៉ុណ្ណោះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

តើបើសិនជាមានការអនុញ្ញាតពីខ្ញុំសូមឲ្យដាក់បញ្ចូលលេខ ERN របស់ឯកសារនេះនៅក្នុងកំណត់ត្រា ។ តើយើងអាចដាក់នៅក្នុងកំណត់ត្រាបានទេនូវលេខ ERN ដែលមានលេខ 00155576?

**ប្រធានអង្គជំនុំ៖**

ចាត់បញ្ចូលតាមកំណត់ហេតុប្រតិចារឹក ពីព្រោះឯកសារត្រូវបានពិនិត្យរួចហើយ ។ ហើយអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ។

*[សវនាការសម្រាកពីម៉ោង១០:៤៤ នាទី ដល់ម៉ោង១១:០៦នាទី]*

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយចុះ ។ យើងបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ហើយសូមអញ្ជើញលោកចៅក្រម យ៉ា សាខន បន្តកិច្ចការងាររបស់លោកតទៀត ។

**ចៅក្រម យ៉ា សុខន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ជនជាប់ចោទ សូមលោកបញ្ជាក់បន្ថែមទៀតមកមើល តើចំណុច “A”, “B”, “C”, “G” តើជាទីតាំងសួរចម្លើយ ឬគ្រាន់តែជាទីតាំងលោកទៅជួបនឹងមេរបស់លោក?

*(មានបញ្ហាមីក្រូហ្វូន)*

សូមលោកបញ្ជាក់ម្ដងទៀតថានៅចំណុច “A”, “B”, “C”, “G” តើជាទីតាំងសួរចម្លើយ ឬគ្រាន់តែជាទីតាំងដែលលោកទៅជួបមេរបស់លោកតែប៉ុណ្ណោះ? ហើយនៅពេលដែលលោកឡើងជាប្រធានមន្ទីរ ស-២១ នោះ តើទីតាំងមន្ទីរ ស-២១ នោះនៅទីណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម “A” ជាទីតាំងដែលៗការចាត់តាំង ស-២១ ដំបូង ។ ដូច្នេះខ្ញុំធ្វើការបានជាមួយលោកគ្រូ សុន សេន ជាមួយនឹង ណាត តែនៅម្ដងគត់នៅទីតាំង “A” នេះ។

ទីពីរ ទីតាំង “B” ។ ទីតាំង “B” នេះ ជាទីតាំងដែលខ្ញុំទៅធ្វើការជាមួយនឹងលោកគ្រូ សុន សេន តាមការកោះហៅប្រហែល (សូមទោស) ប្រហែលពីខែតុលា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃ១៥ សីហា ១៩៧៧ ។ ដូច្នេះ គឺធ្វើការជាមួយនឹងមេអាពីរហ្នឹង តែមេឈ្មោះ សុន សេន ។ ហើយទីតាំង “C” នេះជាទីតាំងដែលខ្ញុំជួប ពូនួន គឺ នួន ជា ទីតាំងនេះខ្ញុំធ្វើការជាមួយនឹងគាត់បានប្រហែលជាបីដងប៉ុននុ៎ង ។ ហើយទីតាំង “G” នេះគឺជាទីតាំងដែលខ្ញុំធ្វើការជាមួយនឹង ពូនួន ហួរហៃ ប្រហែលជា រហូតដល់ ថ្ងៃ៣ មករា ១៩៧៩ ។ ដូច្នេះ “G” នេះ ហើយនិង “C” អម្បាញ់មិញនេះ គឺទីតាំង ដែលខ្ញុំធ្វើការជាមួយនឹងមេឈ្មោះ នួន ជា ។

**ស៖** នៅពេលលោកចាត់តាំងជាប្រធានស-២១ តើទីតាំងមន្ទីរស-២១ ពេលនោះនៅទីណា?

**ឆ៖** ទីតាំងមន្ទីរស-២១ នេះ ដូចខ្ញុំគូរអ៊ីចឹង ខាងជើងផ្លូវលេខ៣១០ ខាងត្បូងផ្លូវលេខ៣៦០ ក៏ប៉ុន្តែមានឈានចូលទៅអគារម៉ាជួរដែរ នៅផ្លូវលេខ អ្ហ៎!នៅខាងត្បូងផ្លូវលេខ៣៦០នេះ ។ ដូច្នេះសរុបមក យើងអាចនិយាយបានថា ស-២១ នៅចន្លោះផ្លូវលេខ៣១០ និងផ្លូវលេខ៣៦០ ផ្លូវព្រះមុនីវង្ស និងផ្លូវ ១៤៣ (សុំទោស) ១៦៣ ខាងត្បូងផ្លូវ១៦៣ ខាងជើងផ្លូវព្រះមុនីវង្ស (សុំទោស) ខាងលិចផ្លូវ១៦៣ នេះខាងលិច ខាងលិចគឺផ្លូវ១៦៣ ខាងកើតគឺផ្លូវព្រះមុនីវង្សខាងត្បូងផ្លូវលេខ៣៦០ ខាងជើងផ្លូវលេខ៣១០។

**ស៖** តើនៅពេលណាមន្ទីរស-២១ ផ្លាស់ទៅវិទ្យាល័យពញ្ញាយ៉ាត តាមគំនិតផ្តួចផ្តើមរបស់អ្នកណា? ហើយដោយមូលហេតុអ្វី? ហើយនិងមានការអនុញ្ញាតពីខាងណាមកទេ?

**ឆ៖** ជម្រាបប្រសាសន៍ លោកចៅក្រម ពេលដែលដំបូងនៅឡើយ ទោះបីខ្ញុំបាទឡើងធ្វើជាប្រធានមកហើយក៏ដោយ ក៏ការសួរចម្លើយនៅកែងផ្លូវលេខ៣៦០និង១៦៣ ។ ដោយខ្ញុំឃើញការលំបាកក្នុងរឿងឃុំឃាំងហើយនិងសួរចម្លើយ ខ្ញុំក៏សម្រេចចិត្តស្នើសុំមេខ្ញុំលោកគ្រូ សុន សេន ប្រើវិទ្យាល័យពញ្ញាយ៉ាតជាទីតាំងសម្រាប់ឃុំឃាំងផង សួរចម្លើយផងនៅទីនោះ ។ គាត់យល់ស្រប ។

សរុបមក ខ្ញុំផ្លាស់ទីតាំងពីកាច់ជ្រុងផ្លូវលេខ១៦៣ និងផ្លូវលេខ៣៦០នេះ មកក្នុងទីតាំងវិទ្យាល័យពញ្ញាយ៉ាត ប្រហែលជានៅក្នុងខែមីនា ឬមេសា ១៩៧៦ ។ ប៉ុន្តែ និយាយឲ្យចំមួយម៉ាត់គឺក្រោយខ្ញុំឡើងជាប្រធាន ។ សរុបមក គំនិតផ្តើមគឺរបស់ខ្ញុំ ។ អ្នកដែលយល់ស្របគឺមេខ្ញុំលោកគ្រូ សុន សេន ។ គោលគំនិតគឺ ឲ្យវាស្រួលឃុំឃាំងនិងស្រួលសួរចម្លើយ ការពារការរត់លួន ។

**ស៖** តើទីតាំងនោះ លោកប៉ាន់ប្រមាណមើលមានទំហំប្រហែលប៉ុនណា? មានព្រំប្រទល់ពីណាទៅណា? ហើយក្នុងនោះមានអគារប៉ុន្មាន?

**ឆ៖** ជម្រាបប្រសាសន៍ លោកចៅក្រម ។ ទីតាំងនោះបើនិយាយអំពីក្រឡាផ្ទៃគឺទំហំខ្ញុំបាទប៉ាន់ប្រមាណមិនត្រូវទេ ។ គ្រាន់តែសូមបញ្ជាក់ថា កន្លែងឃុំឃាំងនិងកន្លែងសួរចម្លើយប្រើអគារទាំងបួននៃវិទ្យាល័យពញាយ៉ាត ។ ទីចាត់ការចាស់របស់វិទ្យាល័យពញាយ៉ាត យើងខ្ញុំប្រើជាកន្លែងការិយាល័យដោយឡែកសាលាបឋមសិក្សាទួលស្លែង យើងខ្ញុំប្រើជារោងជាង ឯចំណែកពួកអ្នកទោសពិសេស សួរនៅខាងត្បូងៗទីតាំងរបស់វិទ្យាល័យពញាយ៉ាត ។ ដូច្នេះ ពួកពិសេសសួរនៅនុ៎ង ឯចំណែកពួកយួនសួរនៅខាងជើង (សុំទោស) ខាងកើតវិទ្យាល័យពញាយ៉ាត ។ សូមចប់បាទ, ខ្ញុំសរុបបានតែប៉ុណ្ណឹងទេ ខ្ញុំមិនវាស់ក្រឡាផ្ទៃដីមិនបានទេ ។

[១១:២០:00]

**ស៖** អគារនៅទីនោះមានប្រាំមែនទេ អគារ “A”, “B”,“C”,“D” និង “E”?

**ឆ៖** បាទ, អគារទាំងអស់មាន៥ ។

**ស៖** តើអគារ “ក” សម្រាប់ធ្វើអ្វី? អគារ “ខ” សម្រាប់-- អគារ “A” សម្រាប់ធ្វើអ្វី? អគារ “B” សម្រាប់ធ្វើអ្វី? អគារ “C”, “D” និង “E”?

**លោក ហ្វ្រង់ស្វ័រ រូ៖**

អគារស-២១ គឺជាកន្លែង វាមានផែនទីដែលបានបង្ហាញជូនពីខាងដើមមួយជាគំនូសផែនទី ហើយយើង ប៉ុន្តែដែលលោកចៅក្រមពិភាក្សាជាផែនទីផ្សេងទេ ឥឡូវនេះ ។

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធាន តើតំណាងអយ្យការអាចឲ្យលោកប្រធានយករូបណាមួយ នេះជារូបរបស់-- ដើម្បីយកទៅបញ្ចាំងដើម្បីឲ្យងាយយល់ពីទីតាំងរបស់អគារនៅក្នុងមជ្ឈមណ្ឌលវិទ្យាល័យពញាយ៉ាតហ្នឹង មាននៅក្នុង-- ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកផែននោះយកទៅដាក់បញ្ចាំង មុននឹងចាប់ផ្ដើមសួរពាក់ព័ន្ធជាមួយនឹងទីតាំងនៃស-២១ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំសូមកាត់បន្តិចហ្នឹង គឺថាវាមានអាចនឹងជួយបន្ថែមប្រសិនជនជាប់ចោទអាចបំភ្លឺ តើកន្លែងណាជាពញាយ៉ាត? ជាលីសេ ពញាយ៉ាត កន្លែងណាទួលស្លែង បឋមសិក្សា

ទូលស្លែង? បើមិនអ៊ីចឹងទេ យើងនឹងមិនមានការច្រឡំគ្នារវាងទីតាំងទាំងពីរនេះ ។

**លោក ហ្វេង់ស្វ័រ រូ៖**

មុននឹងធ្វើដូច្នោះ ខ្ញុំគិតថា លេខERN នៃឯកសារគួរតែបញ្ជាក់ផងដែរ ដើម្បីឲ្យច្បាស់លាស់ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអភ័យទោសលោកប្រធាន ប្រហែលជាអាចនឹងដាក់នៅលើអេក្រង់ ខ្ញុំមិនមានសរសេរលេខ ERN នៅក្នុងឯកសាររបស់ខ្ញុំ ព្រោះសហសេវិករបស់ខ្ញុំបានលើកឯកសារហ្នឹងមកបង្ហាញ ។ ប្រសិនបើអង្គភាពខាងសោតទស្សន៍អាចប្តូរទៅលោក ហ្វូដ គាត់អាចបង្ហាញបន្ថែមនេះ នៅក្នុងអេក្រង់ ទាំងមូលយើងឃើញ--

[១១:២៤:៤៧]

សូមអភ័យទោសលោកប្រធាន នេះជាផ្នែកមួយនៃការបង្ហាញរបស់ខាងៗសោតទស្សន៍ គឺទាក់ទងទៅហ្នឹង ភស្តុតាងដោយ *ហ្សូរ៉ាន់ ឡេស៊ិក (Zoran Lesic)* ។ នេះផ្នែកមួយនៃឯកសារ ដែលបង្ហាញនៅក្នុងប្រព័ន្ធសោតទស្សន៍របស់យើងដែរ ។ យើងមានគោលបំណងនៅដំណាក់កាលក្រោយ ដើម្បីដាក់ជូនទៅអង្គជំនុំជម្រះ ហើយសហសេវិករបស់ខ្ញុំបានលើកឡើងពេលនេះហើយ។ ដូច្នេះយើងអាចហ្នឹងកំណត់យក ឯកសារនេះយកឯកសារនេះមកបង្ហាញដែរ ។

**លោក តាន់ សេណារ៉ុង៖**

បាទ, ខ្ញុំសូមបញ្ជាក់ថែមទៀតដែរ ដើម្បីឲ្យជនជាប់ចោទហ្នឹងបញ្ជាក់ឲ្យច្បាស់ថា នៅក្នុងរូបភាពដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញាហ្នឹង បើសិនជាខ្ញុំមិនច្រឡំទេ អាចខាងក្រោយអគារ“C” និង “B” នោះ អាចជាអតីតសាលាបឋមសិក្សាពញាយ៉ាត ។ អ៊ីចឹងសូមជនជាប់ចោទនោះអាចបញ្ជាក់បន្ថែម មើលថាតើអានេះរូបបច្ចុប្បន្នហ្នឹង ថាតើខាងក្រោយហ្នឹង អាវាជាអតីតសាលាបឋមសិក្សាហ្នឹង ទូលស្វាយព្រៃ-- ទួលស្លែងហ្នឹងមែនទេ? បើឥឡូវវាក្លាយទៅជាផ្ទះល្វែងអស់ហើយ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវសូមផ្តែកលើ នៅផែនទីនេះដែលមានការពាក់ព័ន្ធនឹងសំណួរដែលលោកចៅក្រម យ៉ា សុខន បានសួរលោកអំពីទីតាំងនៃមន្ទីរស-២១ មានទាំងទីតាំងស្នូល មានទាំងទីតាំងនៅជុំវិញមន្ទីរស-២១ ។ ហើយរួចទាំងអគារនានាដែលនៅក្នុងទីតាំងមន្ទីរស-២១ ផង ។ សូមលោកបង្ហាញដោយផ្អែកលើទីតាំង

នេះនៅអគារនៅចំណុចនានាដែលមានការពាក់ព័ន្ធនឹងមន្ទីរស-២១ ។ យល់ទេ?

[១១:២៧:០៨]

**ឆ៖** អរគុណលោកប្រធាន ។ ផែនទីនេះថ្វីត្បិតតែមិនមែនជាគំរោងផែនទីដែលខ្ញុំគូសជូនការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ខ្ញុំសូមអធិប្បាយតាមការបំភ្លឺរបស់លោកព្រះរាជអាជ្ញាអម្បាញ់មិញរួមគ្នានឹងផែនទីនេះផងដែរ ។

កាលពីសម័យនោះវិទ្យាល័យពញាយ៉ាត ដែលអគារ “A”, “B”, “C”, “D” ហើយនិង “E” នេះនៅជាប់គ្នានឹងសាលាបឋមសិក្សាទួលស្វាយព្រៃៗនៅពីខាងលិចហ្នឹងរបងជាប់គ្នា ។ ដល់ឥឡូវ វាក្លាយទៅជាផ្ទះល្វែងហើយ ទុកអាបញ្ហានេះមួយឡែក ។ អគារ“D”, “C” ហើយនិង “B” ជាអគារឃុំឃាំង។ ឃុំឃាំងជនរងគ្រោះដែលទៅជាប់ទោសទាន់នៅទីនោះ គឺនៅអគារ “D”, “C” ហើយនិង “B” ។

អគារ “A” ដែលនៅខាងត្បូងទីនេះ ជាកន្លែងសម្រាប់សួរចម្លើយ ។ គុកពិសេសនៅខាងត្បូងអគារ“A” នេះទៅទៀត ។ ឯចំណែកកន្លែងសួរឃ្លួននៅខាងកើត មិនដឹងជាកូនផ្លូវណាមួយទេ ខ្ញុំវង្វេងហើយ ។ ដូច្នេះខ្ញុំសូមអធិប្បាយប៉ុណ្ណឹងផែនទីនេះ ។ (សុំទោសៗ) សូមបញ្ជាក់ថា អគារ “E” នេះជាកន្លែងសម្រាប់ថតរូប កន្លែងសម្រាប់ធ្វើបញ្ជីមួយរយ ដល់ក្រោយមកប្រើជារោងជាងសម្រាប់គូរនិងឆ្លាក់ ។ ដូច្នេះ បញ្ចប់ការអធិប្បាយអំពីផែនទីស-២១ មន្ទីរ ឃុំឃាំងរបស់ ស-២១ ប៉ុណ្ណេះ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអភ័យទោសខ្ញុំសូមកាត់ម្តងទៀតដែលខ្ញុំចង់ឲ្យកត់ត្រាឲ្យបានច្បាស់ ថាតើឯកសារនេះដកចេញមកពីណា? ហើយថាតើឯកសារនេះជាអ្វី? ដើម្បីកុំឲ្យមានមន្ទិលសង្ស័យក្នុងកំណត់ត្រា នេះជាផ្នែកមួយនៃការបង្ហាញដូចដែលខ្ញុំបញ្ជាក់ ដែលនៅក្នុងសារព័ត៌មាន ឌីវីឌី (DVD) មកពី *ហ្វ្រង់ឡេស៊ិក* ឯកសារនៅក្នុងសំណុំរឿង D៤៥ លើ១ លើ១ (D៤៥/១/១) ចុះថ្ងៃទី៥ ឧសភា ២០០៨ ។ ឯកសារERN ដំបូងនោះ គឺ0018928868 ជាសេចក្តីថ្លែងការណ៍ដែលផ្តល់ឡើងដោយ *ហ្វ្រង់ឡេស៊ិក* ដែលរៀបរាប់អំពីកាសែតឌីវីឌី ដែលអ្វីលោកចៅក្រមបានឃើញរូបភាពនៅលើអេក្រង់នេះ ។ សហព្រះរាជអាជ្ញាថា មានគោលបំណងនៅក្នុងដំណាក់កាលក្រោយណាមួយ ដើម្បីផ្តល់ជូនតុលាការដើម្បីជាជំនួយនូវឯកសារលើក្រដាសនូវរូបភាពមួយចំនួនដែលដកស្រង់ពីឯកសារឌីវីឌីនេះ យើងមានគ្រប់គ្រាន់នូវឯកសារនេះដើម្បីចែកជូនដើម្បីជាជំនួយដល់អង្គជំនុំជម្រះ ។ ឯកសារទាំងនេះដូចដែលខ្ញុំបញ្ជាក់ជាផ្នែកនៃសំណុំរឿង ហើយឯកសារលើក្រដាសនោះ គឺយើងបានដកស្រង់ចេញពីកាសែតឌីវីឌី ត្រូវបាន

ដាក់នៅថ្ងៃ២១ ខែមេសា ។ ហើយនិងជាផ្នែកនៃសេចក្តីស្នើសុំដែលដាក់ជូនសហព្រះរាជអាជ្ញាសុំស្នើសុំឱ្យតុលាការណែនាំដើម្បីឱ្យយើងដាក់ឯកសារជូនដើម្បីបង្ហាញដឹងថា យើងលើកឡើងមុនពេលដែលយើងគ្រោងនៅព្រឹកនេះ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

ម្តងទៀតសហព្រះរាជអាជ្ញាចង់និយាយយ៉ាងម៉េច? ឱ្យច្បាស់លាស់មើល! ឆ្លងកាត់ការបកប្រែហ្នឹង ដូចជាការស្តាប់នៃខ្លឹមសារនៃការប៉ុនប៉ងលើកឡើងរបស់សហព្រះរាជអាជ្ញាមិនច្បាស់លាស់ ។

[១១:៣៥:០០]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ សហព្រះរាជអាជ្ញាបានដាក់នៅក្នុងវិធាន៨២ នៅក្នុង៣ថ្ងៃកន្លងមកនេះ ទាក់ទងទៅនឹងការជូនដំណឹងពីឯកសារ-- ជូនដំណឹងដល់អង្គជំនុំជម្រះអំពីឯកសារដែលខ្លួនចង់ដាក់ជូនអង្គជំនុំជម្រះដែលយកចេញពីសំណុំរឿង ។ ហើយខ្ញុំអាចនឹងជូនទៅចៅក្រម ទៅនឹងមេធាវីការពារ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងទៅជនជាប់ចោទនូវឯកសារនៃវិធាន៨២ ដែលជាសេចក្តីស្នើសុំរបស់យើង ។ ដោយនិយាយសង្ខេបបានឯកសារនោះរៀបរាប់ពីឯកសារដែលនិយាយ ដែលយើងបញ្ជាក់ថា មានការទាក់ទងទៅនឹងបញ្ហានេះ និយាយអំពីការបង្កើតស-២១ ។

ជាគោលការណ៍វាពាក់ព័ន្ធទៅនឹងឯកសារឌីវីឌី របស់ *ហ្សូរ៉ាន់ឡេស៊ិក* ដែលជាអ្នកជំនាញដែលទទួលបានការតែងតាំងដោយសហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់នូវកាសែតសោតទស្សន៍អំពីបរិវេណជុំវិញនៃស-២១ នៅជើងឯងផងដែរ ហើយនិងភ្នំពេញទៀត ។ ហើយសំណុំឯកសារដែលសហព្រះរាជអាជ្ញាបានមួយដុំនេះ ដែលបានចងក្រងដើម្បីជួយដល់ភាគីទាំងអស់នោះ ។ ឯកសារនោះបង្ហាញអំពីនូវរូបថតបច្ចុប្បន្នដែលមាននៅក្នុងឌីវីឌី ។ បើសិនជាលោកលោកស្រីចៅក្រមអនុញ្ញាតយើងខ្ញុំនឹងចែកជូននូវពេលនេះ ខ្ញុំនឹង មុននឹងពន្យល់តទៅទៀតនូវឯកសារទាំងអស់នេះ ។ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

ជាការល្អ ហើយអង្គជំនុំជម្រះអនុញ្ញាតតាមការលើកស្នើសុំនេះ ។ សូមចាត់ចែងលោកសហព្រះរាជអាជ្ញា ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំយល់ថាមានសំណើនៅពេលនេះ ដែលស្នើដោយសហព្រះរាជអាជ្ញាទាក់ទងទៅនឹងថា តើឯកសារនេះគួរគប្បីទទួលយកដោយអង្គជំនុំជម្រះ ឬអត់? ប៉ុន្តែ ខ្ញុំមិនចង់ឲ្យឯកសារនឹងចែកមុនពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចទេ ។ ប្រសិនបើយើងដោះស្រាយករណីនេះដោយសេចក្តីស្រង់ពីឯកសារ ដែលមាននៅក្នុងសំណុំរឿងរួចហើយដែលថាដកស្រង់ពីសំណុំរឿង ប៉ុន្តែយើងនិយាយពេលនេះអំពីការងារដែលធ្វើដោយសហព្រះរាជអាជ្ញា ដែលសម្រាប់ជាអត្ថប្រយោជន៍របស់ខ្លួនឯងដែលខ្លួនចង់ចែករំលែកនៅក្នុងអង្គជំនុំជម្រះហើយជាឯកសារថ្មី ហើយសំណើនោះមេធាវីក៏មានសិទ្ធិដើម្បីលើកឡើងពីបញ្ហានេះដែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

[១១:៣៨:១៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើសហព្រះរាជអាជ្ញាមេត្តាបញ្ជាក់ថា តើឯកសារនេះដែលដាក់បញ្ចូលដែលឯកសារដាក់បញ្ចូលទៅក្នុងសំណុំរឿង ឬក៏ឯក-- លោកចង់និយាយពីឯកសារដែលមានយោបល់របស់ខ្លួលដែលថាវាមានជាកាលវិភាគរបស់សហព្រះរាជអាជ្ញា ហ្នឹងហើយដែលអង្គជំនុំជម្រះចង់ដឹង ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន នេះជាឯកសារចាស់ដែលមាននៅក្នុងសំណុំរឿង មិនមែនឯកសារថ្មីទេ ។ ឯកសារនេះត្រូវចែកជូន គឺដើម្បីឲ្យមេធាវីការពារឲ្យតុលាការបានជ្រាបកាន់តែច្បាស់ គឺថាមានតែឯកសារមួយទំព័រទេដែលបង្ហាញនៅក្នុងអេក្រង់នៅពេលតែមួយ ។ នេះហើយជាឯកសារបំពេញបន្ថែមឲ្យភាគីបានយល់ ឲ្យបានមើលលម្អិតជាជាងដោយមិនចាំបាច់មើលតែឯកសារតែម្តងមួយម្តងៗនៅក្នុងអេក្រង់ ។ អ៊ីចឹងហើយឯកសារទាំងអស់នេះ គឺស្ថិតនៅក្នុងសំណុំរឿង ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងការជំទាស់របស់លោកមេធាវី ហ្រ្វង់ស្វ័រ រូ មិនមានប្រសិទ្ធភាពទេ ។ អាហ្នឹងយើងបានសម្រេចរួចហើយ ហើយអនុវត្តតាមការសម្រេចនេះ ។ ហើយជាកិច្ចបន្តសូមអញ្ជើញលោកចៅក្រមបន្តដំណើរការនីតិវិធីតាំងសំណួរដល់ជនជាប់ចោទជាបន្តទៅទៀត ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** នៅក្នុងអគារ “D”, “C”, “B” តើមានអគារណាដែលមានខ័នជញ្ជាំងជាបន្ទប់តូចៗដាក់អ្នកទោសសម្រាប់ម្នាក់ៗ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម តាំងពីគេកសាង*សេលុល* តាមបញ្ជារបស់ខ្ញុំ ខ្ញុំមិនដែលបានចូលទៅអើតនៅខាងក្នុងនេះទេ ។ សូមបញ្ជាក់បន្ថែមឲ្យច្បាស់ថា តាំងពីគេធ្វើ *សេលុលអាំងឌីវីឌុយអែល* តាមបញ្ជារបស់ខ្ញុំ ខ្ញុំអត់ដែលបានចូលទៅអើតកន្លែងនេះទេ ។ ក៏ប៉ុន្តែ តាមការដែលថ្ងៃចៅក្រមស៊ើបអង្កេតនាំខ្ញុំយកទៅបង្ហាញកន្លែងចាស់ ខ្ញុំគិតថាមានតែអគារ “B” ហើយនិង “C” ប៉ុណ្ណោះដែលមាន *សេលុលអាំងឌីវីឌុយអែល* ។ ចំណែកអគារ“A” ដែលនៅខាងត្បូងគេ ជាកន្លែងសម្រាប់សួរចម្លើយ។ ឯចំណែកឯអគារ“D” នៅពីខាងជើងជាកន្លែងដែលឃុំឃាំងអ្នកទោស ។ ដូច្នេះ ខ្ញុំសូមសរុបតាមការដែលឃើញហើយចងចាំក្រោយពេលទៅបង្ហាញទីតាំង ។

[១១:៤៣:០៧]

**ស៖** សូមមន្ត្រីតុលាការបង្ហាញឯកសារដែលមានលេខ E0015228 នៅលើអេក្រង់ ។ អង្គការលេខនេះ លោកជាអ្នករៀបចំ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ ខ្ញុំរៀបចំអង្គការលេខនេះដោយផ្ទាល់ដៃ ។

**ស៖** តើមានការសម្រេចពីអ្នកណាមកទេ?

**ឆ៖** គ្មានអ្នកណាមានឥទ្ធិពលលើខ្ញុំក្នុងការរៀបចំអង្គការលេខនេះទេ ។ វាគ្រាន់តែឈរលើការចងចាំរបស់ខ្ញុំបានកម្រិតនោះនៅក្នុងពេលនោះ នៅក្នុងពេលធ្វើអង្គការលេខនេះ ។

**ស៖** លោកប្រធានរបស់លោកឈ្មោះ-- គាត់មានភារកិច្ចធ្វើអ្វីនៅពេលនោះ?

[១១:៤៦:០២]

**ឆ៖** លោកចៅក្រមជាទីគោរព ចំពោះមិត្ត ឃឹម វ៉ាក ហៅ ហ៊ី នេះការងារប្រចាំថ្ងៃរត់គ្រប់យ៉ាងនៅស-២១ ហ្នឹង គ្មាគ្មានស្វាងទេ ។ នេះជាការពិត ។

**ស៖** សូមលោកបញ្ជាក់ឲ្យច្បាស់លាស់មើល តើគាត់គ្រប់គ្រងអ្វីខ្លះ? ហើយគាត់ទទួលបង្គាប់បញ្ជាពីអ្នកណា?

**ឆ៖** ទីមួយសូមបញ្ជាក់ជូនអំពីបញ្ហាបង្គាប់បញ្ជា ។ ការងារដាច់ដោយឡែកបានន័យថា លើសពីគោលការណ៍ប្រចាំថ្ងៃដែលគាត់ទទួលភារៈគឺខ្ញុំជាអ្នកបញ្ជា ។ ខ្ញុំនិយាយប៉ុណ្ណោះដើម្បីត្រឡប់ទៅរក

ការងារស្ទី ដែលគាត់ប្រតិបត្តិការជាយុត្តិសាស្ត្រតាំងពីកកើតស-២១មក ។ ស-២១ កកើតឡើងមានការងារមួយចំនួនដែលគាត់ត្រូវតែបំពេញជាកាតព្វកិច្ចដោយខានមិនបាន ។ ដូចជា ត្រួតពិនិត្យលើការការពារ ត្រួតពិនិត្យលើការទទួលជនរងគ្រោះដែលគេបញ្ជូនមកចូលមន្ទីរស-២១នេះ ត្រួតពិនិត្យមើលការនាំមនុស្សចេញទៅជើងឯក ចេញបញ្ជាភ្លាមៗកាលណាមានបាតុភាពបះបោរនៅក្នុងកន្លែង មុននឹងរាយការណ៍មកខ្ញុំៗ ។ ដូច្នេះទន្ទឹមនេះ ក៏មានការងារផ្សេងទៀតដែរ ដូចជាការងារបង្កបង្កើនផលការងារចិញ្ចឹមអង្គភាព ការងារសុខភាព ហើយនិងការអនុវត្តបទបញ្ជាហើយនិងវិន័យទៅលើអង្គភាពទាំងមូល នេះជាកិច្ចការប្រចាំថ្ងៃរបស់គ្នា ។

ឯចំណែកការងារដែលខ្ញុំបាទហៅថាដោយឡែក ដូចជាការងារដែលឲ្យគាស់យកឆ្អឹងចេញពីគុកតាខ្មៅហើយយកមកដុត អាហ្នឹងការងារដោយឡែកហើយ ។ ការងាររង់ចាំចាប់អ្នកណានៅហ្នឹងផ្ទះខ្ញុំហ្នឹងក៏ជាការងារដោយឡែក ។ ឧទាហរណ៍ការងារមួយទៀត ការនាំចេញៗមនុស្សសំខាន់ៗដែលត្រូវតែថត ក៏ខ្ញុំបញ្ជា ។ កាលណាបានទទួលបញ្ជាពីលើមកខ្ញុំហៅគាត់មកភ្លាមមកទទួលបញ្ជាពីខ្ញុំយកទៅអនុវត្ត ។ សរុបមក វាមានការងារដែលគាត់ត្រូវធ្វើជាប្រចាំថ្ងៃ វាមានការងារដែលត្រូវតែចាំទទួលបញ្ជាពីខ្ញុំសិនសឹមធ្វើ ។

**ស៖** តើលោក នុន ហ៊ុយ គាត់មានភារកិច្ចធ្វើអ្វីដែរ ដែលជាអនុប្រធាន ជាសមាជិកនៃគណៈកម្មាធិការ ស-២១នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម មិត្តហ៊ុយ ឈ្មោះដើម នុន ហ៊ុយ នេះ មានភារកិច្ចផ្តាច់មុខនៅខាងព្រៃស ។ គាត់មានភារកិច្ចផ្តាច់មុខៗនៅខាងព្រៃស ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! លោកកុំអាលឆ្លើយដោយសារមានបញ្ហាការបកប្រែភាសា។ មន្ត្រីតុលាការសម្របសម្រួលខាងបកប្រែភាសា ។

*(មានបញ្ហាបកប្រែភាសាពីម៉ោង១១:៥៣:១៤នាទី ដល់ម៉ោង១១:៥៤:៥៤ នាទី)*

ចាប់ផ្តើម- សូមជនជាប់ចោទឆ្លើយម្តងទៀតនូវអ្វីដែលលោកត្រូវឆ្លើយចុងក្រោយអម្បាញ់មិញនេះ ដោយសារមានបញ្ហាការបកប្រែ ។ អ៊ីចឹងគ្រាន់តែនិយាយបញ្ជាក់ឡើងវិញ ។

**ឆ៖** សូមអរគុណលោកប្រធាន ។ មិត្តហ៊ុយ ឈ្មោះដើម នុន ហ៊ុយ នេះ មានភារកិច្ចនៅឯខាងព្រៃស ។ ភារកិច្ចទីមួយគឺ ដឹកនាំកម្លាំងទាំងអស់បង្កបង្កើនផល ។ ទីពីរ គឺអប់រំសាឡើងវិញចំពោះ

សមាសភាពដែលមានបញ្ហា ។ នេះជាភារកិច្ចប្រចាំថ្ងៃរបស់ មិត្តហ៊ុយ ។ ដោយឡែក ពេលណាមានបាតុភាពត្រូវបញ្ជូនអ្នកដែលស្ថិតនៅក្នុងការអប់រំនេះមកមន្ទីរស-២១ ឯភ្នំពេញគឺត្រូវសុំយោបល់សម្រេចពីខ្ញុំ ឬក៏មិត្តហ៊ី ។ ជាទូទៅគាត់សុំយោបល់សម្រេចពី មិត្តហ៊ី ក៏ប៉ុន្តែមានករណីខ្លះ តម្រូវឱ្យសុំសេចក្តីសម្រេចពីខ្ញុំ ព្រោះមេផ្តាំផ្តាច់ ។ ដូច្នេះសូមបញ្ចប់អំពីករណីកិច្ចរបស់ មិត្តហ៊ុយ នៅឯស្រែប៉ុណ្ណេះ ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** ចំពោះភារកិច្ចរបស់លោកជាប្រធាន លោកមានភារកិច្ចអ្វីខ្លះ?

**ឆ៖** ខ្ញុំជាប្រធានភារកិច្ចសំខាន់ ហើយមានលក្ខណៈចាក់ជ្រៅជាខ្លឹមសារទៅខាងឧក្រិដ្ឋកម្មជាងគេបង្អស់ ។ សេចក្តីរាយការណ៍ចម្លើយសារភាព សេចក្តីរាយការណ៍ជាសារភាពរបស់ជនរងគ្រោះដែលយកចម្លើយបានដោយទារុណកម្ម គឺខ្ញុំហើយអ្នកគួសពីក្រោមដើម្បីឱ្យមេស្រួលយល់ ។ ដូច្នេះសេចក្តីសារភាពមួយដែលយើងខ្ញុំរុញទៅលើ វាត្រូវជាប់ជំពាក់ជំពិនដល់មនុស្សទៀតជាច្រើន ។

ទីពីរ ការអប់រំរៀនសូត្រដែលជំរុញឱ្យគេហ៊ានសួរ ហ៊ានធ្វើទារុណកម្ម មានពិសោធន៍ក្នុងការសួរ វាសុទ្ធតែនាំមកនូវការដែលចាប់មនុស្សថ្មីថែមទៀត មនុស្សដែលកំពុងតែមានសេរីភាព យើងត្រូវឱ្យមានចម្លើយឆ្លើយដាក់គេ ។ នេះការងារខ្ញុំដែលនៅជាប់នឹងមេ ហើយប្រចាំតែរឿងអស់អ៊ីចឹងៗវេទនាណាស់ បើសិនជាឃើញគិតឱ្យជ្រៅទៅ វាខ្លោចផ្សាហើយវាចាក់ជ្រៅទៅខាងឧក្រិដ្ឋកម្មជាងការងារផ្សេងទៀត ។ យុទ្ធជនខ្ញុំ ខួរក្បាលគេស្អាតស្អំ យើងយកមកអប់រំឱ្យគេដាច់ខាតធ្វើទារុណកម្ម ដាច់ខាតសួរ មិនមែនជាបញ្ហាល្អទេ នេះជាការងារដែលខ្ញុំកាន់កាប់ ។ ខ្ញុំសូមសរុបខ្លីការងាររបស់ខ្ញុំប៉ុណ្ណេះក្រៅអំពីបញ្ហាដោយឡែកៗ ។

**ស៖** តើអង្គភាពសួរចម្លើយអ្នកណាជាអ្នកគ្រប់គ្រង?

**ឆ៖** គ្រប់គ្រងប្រចាំជីវភាពប្រចាំសប្តាហ៍ មិត្តហ៊ី អ្នកគ្រប់គ្រង ។ ក៏ប៉ុន្តែ និយាយឱ្យចំឱ្យច្បាស់ឱ្យជ្រៅទៅទៀតគឺ មេពួកគេមួយក្រុមៗគេអ្នកគ្រប់គ្រង ។ ឯចំណែកខ្ញុំទទួលខុសត្រូវខាងមើលទៅទាស់ ឬក៏ឃើញមានគំនិតអីថ្មីមួយនៅក្នុងខ្លួន ខ្ញុំហៅគេមករៀន ។ ដូច្នេះ ការងាររៀនសូត្រនេះហើយ វាចាក់ជម្រៅជាងអាការងារដែលគេប្រជុំជីវភាពប្រចាំអាទិត្យរបស់គេ ។

[១២:០៣:៣៥]

**ស៖** អង្គភាពសួរចម្លើយនោះមានចែកចេញជាអ្នកសួរចម្លើយអ្នកទោសប្រុស ឬស្រីទេ? ហើយអ្នកនោះអ្នកណាជាអ្នកប្រធានក្រុមខាងអ្នកសួរចម្លើយអ្នកទោសប្រុស ហើយនិងអ្នកសួរចម្លើយអ្នក

ទោសស្រី?

**ឆ៖** អរគុណលោកចៅក្រុម ។ មិត្តប៉ុន ហើយនិងបង ម៉ម ណៃ ដាច់ដោយឡែកតែឯងទេ ។ មួយសួរចម្លើយយួន ហើយនិងជំនួយការខ្ញុំគឺបង ម៉ម ណៃ ។ អ្នកទោស-- អ្នកសួរចម្លើយពីរនាក់ដែលមានលក្ខណៈដាច់ដោយឡែកពីក្រុមគឺ ទីមួយបង ម៉ម ណៃ គាត់សួរចម្លើយយួន ហើយនិងជាជំនួយការរបស់ខ្ញុំ ។ សួរចម្លើយវៀតណាមៗ ហើយនិងជាជំនួយការរបស់ខ្ញុំ ។ ដោយឡែក មិត្តប៉ុន ផ្ដាច់មុខខាងសួរចម្លើយអ្នកទោសសំខាន់ៗ ដូចជា បង ម៉ែន សាន ហៅ យ៉ា អតីតលេខាភូមិភាគព្លិសានអ៊ីចឹង នៅលើដៃ មិត្តប៉ុន ជាអ្នកសួរ ។ ព្លិសានៗ ភូមិភាគព្លិសាន ។ នេះជាឧទាហរណ៍ទេ ដើម្បីបញ្ជាក់ថា មិត្តប៉ុន សួរតែចម្លើយជនរងគ្រោះដែលមានឋានៈខ្ពស់ មានសារសំខាន់ខ្លាំង ។ សរុបមក អ្នកផ្សេងទៀតមានចែកជាបួនក្រុមមាន៖ ក្រុមត្រជាក់ ទីពីរមានក្រុមក្ដៅ ទីបីមានក្រុមអង្កៀម ។ ក្រុមអង្កៀមនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មិត្តទិត ។ ឯចំណែកក្រុមពីរទៀត ខ្ញុំមិនទាន់នឹកឃើញទេ ។

ដូច្នេះ ប្រុសៗមានបីក្រុម។ ឯចំណែកអង្គភាពសួរចម្លើយស្រីនេះៗទើបនឹងកើតទេ ។ អង្គភាពយកមនុស្សស្រីទៅសួរចម្លើយស្រីនេះ ទើបនឹងបង្កើតក្រោយបាតុភាពមួយកើតឡើង ។ បាតុភាពមួយនេះគឺ អ្នកសួរចម្លើយប្រុសទៅរំលោភលើរាងកាយរបស់អ្នកទោសស្រី ដោយយកឈើទៅរុកក្នុងប្រដាប់ភេទរបស់គាត់ ។ កើតរឿងនេះ ខ្ញុំដកអ្នកសួរចម្លើយប្រុសហ្នឹងចេញ ហើយសុំអនុញ្ញាតបង្កើតអ្នកសួរចម្លើយស្រី ដោយប្រមូលប្រពន្ធកម្មាភិបាលទាំងអស់ចូលមក ។ ទាំងអស់មានប្រាំនាក់ អ្នកកម្មាភិបាលស្រី សួរចម្លើយស្រីហ្នឹង កកើតដំបូងមានប្រាំនាក់ ។ ប្រធានស្រីដែលគ្រប់គ្រងកម្មាភិបាលស្រី សួរចម្លើយស្រីនេះឈ្មោះមិត្តម៉ុត ប្រពន្ធមិត្តហ៊ី ។ ប៉ុន្តែដល់ក្រោយមក មានកម្មាភិបាលស្រីសួរចម្លើយស្រីនោះ ពីរនាក់ត្រូវចាប់ខ្លួន ។ ទីមួយគឺ មិត្តពឿន ប្រពន្ធមិត្តម៉េង ទីពីរគឺ មិត្តខឿន ប្រពន្ធមិត្តហ៊ុយ, ហ៊ុយ ព្រៃស មិនមែន ហ៊ុយ ភ្នំពេញទេ ហ៊ុយ ព្រៃស ប្រពន្ធមិត្តហ៊ុយ ព្រៃស ។ ដូច្នេះ នៅសល់តែកម្មាភិបាលស្រី សួរចម្លើយស្រីបីនាក់ ។ ខ្ញុំសូមបញ្ចប់ចម្លើយអំពីកម្មា-ភិបាលសួរចម្លើយ ។

[១២:១១:០៣]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ គឺអង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកសវនាការពិភាក្សាដេញដោលសម្រាប់ថ្ងៃនេះត្រឹមនេះ ។ ហើយអង្គសវនាការនឹងលើកទៅបន្តនៅព្រឹកថ្ងៃច័ន្ទ ទី២៧ ខែមេសា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនតទៅ ។ ដោយមូលហេតុសូមជម្រាបអង្គជំនុំ

ជម្រះទាំងមូលជ្រាបសាឡើងវិញថា សវនាការល្ងាចនេះត្រូវបានផ្អាកដោយមូលហេតុកិច្ចការជាច្រើនរបស់អង្គជំនុំជម្រះត្រូវប្រជុំពិភាក្សាសម្រេចនូវសំណើសុំរបស់ភាគីដែលបានលើកឡើងក្នុងអំឡុងពេលសវនាការប៉ុន្មានថ្ងៃនេះ ។ ហើយនិងកិច្ចការរដ្ឋបាលមួយចំនួនដែលត្រូវចេញសេចក្តីសម្រេចនិងសេចក្តីណែនាំ ។ លោកហ្វ្រង់ស្វ័រ រូ ចង់មានបញ្ហាអីទៀតហើយ?

**លោកហ្វ្រង់ស្វ័រ រូ៖**

មុនពេលលោកសម្រាក ខ្ញុំសុំលើកចំណុចមួយចំនួន ។ មេធាវីការពារមានការកត់សម្គាល់មួយដែលថា វាមានកំហុសឆ្គងច្រើនក្នុងការបកប្រែច្រើនណាស់នៅក្នុងឱកាសជាច្រើន ។ ការបកប្រែបារាំងនោះគឺ មិនបានចង្អុលបង្ហាញគ្រប់ចំណុចនោះទេ ។ ហើយយើងបានពិភាក្សាលើបញ្ហាសំខាន់ណាស់ហើយសុំទាញការចាប់អារម្មណ៍ពីតុលាការ ។ ចំណុចទីពីររបស់ខ្ញុំនោះ គឺលោកប្រធាន គឺថាខ្ញុំសូមត្រឡប់ទៅរកនៅក្នុងការចែករំលែកឯកសាររបស់សហព្រះរាជអាជ្ញា គឺថាមិនបានមានគោលបំណងពីដំបូងដើម្បីចែករំលែកឯកសារនោះភ្លាមៗទេ ។ ពីព្រោះមិនទាន់មានការសម្រេចរបស់អង្គជំនុំជម្រះហើយសុំឱ្យមេធាវីការពារមានឱកាសនឹងឆ្លើយទៅនឹងការស្នើសុំនោះ ។

ខ្ញុំយល់ថា សហព្រះរាជអាជ្ញា ជាបឋមនោះ គឺបានដាក់ពាក្យសុំដើម្បីសុំការអនុញ្ញាតដើម្បីចែកឯកសារនេះ ។ ខ្ញុំសុំឱ្យយើងក៏ចង់បានឱកាសដើម្បីឆ្លើយតបទៅនឹងពាក្យសុំនោះដែរ ។ ប៉ុន្តែ ពេលនោះយើងមិនបានផ្តល់ឯកសារនឹងជាបារាំងទៅខាងមេធាវីការពារ ។ ឯកសារនេះវាលើកឡើងនូវបញ្ហាមួយដែលថាសហព្រះរាជអាជ្ញានោះ ប្រកាន់ជំហរដែលថា ខ្លួនដាក់ឯកសារនោះ ប៉ុន្តែ ខ្លួនមិនបានលើកឡើងពីឯកសារដែលនៅក្នុងសំណុំរឿងដែលថា សហចៅក្រមស៊ើបអង្កេតបានរៀបចំនូវៗ កម្រងរូបថតដែលចេញពីការសម្តែងឡើងវិញនោះ ។ ខ្ញុំនឹងពិនិត្យមើលលើឯកសារ និងរូបភាពទាំងឡាយដែលចេញមកពីសហចៅក្រមស៊ើបអង្កេតពីការសម្តែងឡើងវិញនោះនៅទីកន្លែង ។ មិនមែនជាឯកសាររបស់សហព្រះរាជអាជ្ញាដែលខ្លួនបានធ្វើការវិភាគ ហើយធ្វើយោបល់ក្នុងអត្ថប្រយោជន៍របស់ខ្លួន ។ ខ្ញុំសូមពន្យល់ចំណុចពីរបីនៅក្នុងចម្លើយ ដែលជាចម្លើយដែលខ្ញុំនឹងឆ្លើយតបទៅខាងសហព្រះរាជអាជ្ញាវិញ ។

សូមអរគុណលោកប្រធាន ។

**ចៅក្រម អាឡិចសាន់ឌឺ ប៉ើត៖**

នេះមិនមែនជាជំហររបស់សហព្រះរាជអាជ្ញា មិនមែនជាការវិភាគទេ ។ នេះជាឯកសារដែលយកចេញមកពីសំណុំរឿងតាមការបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ។ ប្រហែលដាក់ចំណងជើង

ខុសនៅក្នុងសេចក្តីសម្រេច៩២ ដែលថា តម្រូវឲ្យមានការឆ្លើយតបហ្នឹងជាបញ្ហាដែលសម្រេចនៅក្នុងការិយាយល័យរបស់យើងក្នុងពេលថ្មីៗនេះ ដែលថា ឯកសារទាំងអស់សហព្រះរាជអាជ្ញាគ្រប់រូបបានព្យាយាមធ្វើហ្នឹង គឺដាក់ឯកសារទាំងអស់នេះចំពោះមុខអង្គជំនុំជម្រះ ដោយហេតុថា ខ្លួនមានសិទ្ធិធ្វើដូចដែលវិធាន៨៧ អនុញ្ញាតហើយមេធាវីក៏មានសិទ្ធិធ្វើដូច្នោះ ។ ប្រសិនបើមានភាគីណាមួយ បើសិនជាមេធាវីការពារចង់ដាក់ឯកសារទៅអង្គជំនុំជម្រះខ្លួនអាចធ្វើដូច្នោះបាន ហើយមិនចាំបាច់ស្នើទេ ។ នេះហើយជាគោលបំណងដែលយើងដាក់ឯកសារនេះ ដើម្បីផលប្រយោជន៍របស់ភាគីទាំងអស់ មិនមែនជាផលប្រយោជន៍របស់ភាគីព្រះរាជអាជ្ញាទេ ។ គឺថាមិនមែនជាការវិភាគទេនៅក្នុងឯកសារនេះ ហើយក៏មិនមែនជាបង្ហាញអំពីទស្សនៈអ្វីមួយរបស់សហព្រះរាជអាជ្ញាក្រៅពីឯកសារសំណុំរឿងនោះដែរ ។

លោក ហ្វេង់ស្វ័រ រូ៖

លោកប្រធាន ។ អ្វីដែលខ្ញុំស្នើសុំនោះ ដោយហេតុថាសហព្រះរាជអាជ្ញាបានដាក់សំណើមេធាវីគប្បីតែមានឱកាសដើម្បីឆ្លើយតបទៅនឹងសំណើដែលដាក់ជូនអង្គជំនុំជម្រះនោះ ។ សូមអរគុណ ។

[១២:១៨:៥៤]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង សាជាថ្មីម្តងទៀត អង្គជំនុំជម្រះសូមជម្រាបទៅមេធាវីការពារក្តីថា អង្គជំនុំជម្រះកត់សម្គាល់នូវអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះ ។ ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបលោកថា អង្គជំនុំជម្រះបានសម្រេចរួចហើយនូវកិច្ចការនេះ ប៉ុន្តែ លោកនៅតស៊ូនៅក្នុងការទាមទារ ។ អង្គជំនុំជម្រះនឹងទទួលនូវការកត់សម្គាល់របស់លោកនេះ សម្រេចនៅថ្ងៃច័ន្ទ ទី២៧ ខែមេសា ខាងមុខ មុននឹងចាប់ផ្តើមដំណើរការសវនាការ ។ ប៉ុន្តែ សូមលោកបញ្ជាក់អំពីឯកសារនានា ដែលបានជូនដោយសហព្រះរាជអាជ្ញារួចហើយនេះ ថាតើឯកសារណាខ្លះដែលមានបញ្ហា? ហើយបញ្ហានោះវាផ្ទុយជាមួយនឹងច្បាប់ ឬផ្ទុយនឹងវិធានឲ្យបានច្បាស់លាស់? ទាំងការបកប្រែទាំងឯកសារដែលលោកយល់ថា អង្គជំនុំជម្រះមិនត្រូវ មិនគួរសម្រេចទទួលទេ ឬក៏ថាការទទួលនេះវាមានកំហុសនោះ?

អ៊ីចឹង ជាកិច្ចបន្តដោយសារពេលវេលាអស់ហើយ ។ អ៊ីចឹងសាជាថ្មីម្តងទៀត គឺអង្គជំនុំជម្រះសម្រេចថាដំណើរការសវនាការថ្ងៃនេះគឺ ផ្អាកត្រឹមនេះ ដោយលើកទៅបន្តសវនាការនៅព្រឹកថ្ងៃច័ន្ទ ទី២៧ ខែមេសា ឆ្នាំ២០០៩ ។ ដោយឡែក គឺអង្គជំនុំជម្រះល្ងាចនេះគឺមិនធ្វើសវនាការទេ ដោយមូលហេតុអង្គជំនុំជម្រះមានភារកិច្ចជាច្រើនត្រូវប្រជុំពិភាក្សាសម្រេចអំពីសំណើសុំនានា ដែលធ្វើឡើងដោយភាគី

ប៉ុន្មានថ្ងៃនៃដំណើរការសវនាការកន្លងមកនេះ ហើយនិងកិច្ចការជាច្រើនទៀតដែលនៅសេសសល់ ត្រូវចេញសេចក្តីសម្រេចជាបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងដំណើរការនៃសវនាការនៅទីនេះឲ្យបានត្រឹមត្រូវ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់ត្រឡប់មកកាន់ទីនេះ នៅព្រឹកថ្ងៃច័ន្ទ ទី២៧ ខែមេសា មុនម៉ោងប្រាំបួនជាកំហិត ។ ហើយជម្រាបដល់ភាគីដែលត្រូវចូលរួមក្នុងសវនាការក៏ដូច្នោះដែរ ក៏សូមអញ្ជើញមានវត្តមាននៅក្នុងសាលសវនាការឲ្យបានមុនម៉ោងប្រាំបួន ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ខាងមុខនេះ ៕

*[សវនាការផ្អាកនៅម៉ោង១២:២១ នាទី]*